# ថុន រឿន : មកដល់ពេលនេះហើយ នួន ជា នៅតែមិនព្រមភ្ញាក់ខ្លួនទៀត

ឌី សុជាតា

នៅព្រឹកថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣នេះ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តបើកសវនាការស្តីពីការដាក់ឯកសារដោយមេធាវីការពារក្តី នួន ជា ។ បន្ទាប់ពីការបញ្ចប់សេចក្តីលើកឡើងរបស់មេធាវីជាតិ និងអន្តរជាតិរបស់ខ្លួន នួន ជា បានធ្វើសេចក្តីថ្លែងការណ៍មួយដែលមានរយៈពេលប្រហែលមួយម៉ោង ដើម្បីឆ្លើយតបនឹងការដាក់ឯកសារភ័ស្តុតាងគន្លឹះរបស់សហព្រះរាជអាជ្ញាបានដាក់កាលពីខែមិថុនា ឆ្នាំ២០១៣ ។

ជនជាប់ចោទ នួន ជា ដែលជាអតីតបងធំទី២នៃរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើសេចក្តីថ្លែងការណ៍ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការថា ការលើកឡើងរបស់សហព្រះរាជអាជ្ញាពុំមានភាពសមស្របនឹងស្ថានភាពជាក់ស្តែងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ ជនជាប់ចោទ នួន ជា បានលើកឡើងនូវចំណុចសំខាន់ៗមួយចំនួនដើម្បីឆ្លើយតបនឹងឯកសារភ័ស្តុតាងរបស់សហព្រះរាជអាជ្ញា ។ ចំណុចទីមួយ ទាក់ទងនឹងការជម្លៀស ប្រជាជនចេញពីទីក្រុងភ្នំពេញ នួន ជា បានបញ្ជាក់ថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញពុំមែនធ្វើដោយការបង្ខំនោះទេ ។ ប្រជាជនចាកចេញពីលំនៅដ្ឋានដោយការស្ម័គ្រចិត្តរៀងៗខ្លួន ។ នួន ជា បានបញ្ជាក់ពីហេតុផលដែលបក្សកុម្មុយនីស្តកម្ពុជាសម្រេចបង្ខំចិត្តជម្លៀសប្រជាជនដោយសារ ទីមួយ ការធានានូវ



ការជម្លៀសប្រជាជនក្រោមរបបខ្មែរក្រហមដែល នួន ជា អះអាងថា ជាការចាកចេញពីផ្ទះដោយការស្ម័គ្រចិត្ត

សុវត្ថិភាពរបស់ប្រជាជនចេញពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។ ទីពីរ កង្វះខាតស្បៀងអាហារសម្រាប់ផ្គត់ផ្គង់ប្រជាជនដោយសារនៅក្នុងកាលៈទេសៈនោះកម្ពុជាជួបប្រទះសង្គ្រាមយូរអង្វែង និងមូលហេតុពុំមានការផ្តល់ជំនួយពីបរទេស ។ ដូច្នេះបក្សកុម្មុយនីស្តកម្ពុជា ពិសេស ប៉ុល ពត បានសម្រេចចិត្តជម្លៀសប្រជាជនដើម្បីធ្វើការបង្កបង្កើនផលនៅតាមជនបទហើយប្រជាជនបានយល់ច្បាស់ពីស្ថានភាពគ្រោះថ្នាក់របស់កម្ពុជានៅពេលនោះ ព្រមទាំងស្ម័គ្រចិត្តចេញពីទីក្រុងភ្នំពេញបន្តបន្ទាប់តាមការអំពាវនាវ ។

ឯកសារភស្តុតាងគន្លឹះដាក់ជូនដោយសហព្រះរាជអាជ្ញានាពេលកន្លងមកបានបញ្ជាក់ថា នួន ជា ជាបុគ្គល ដែលទទួលខុសត្រូវកែសម្រួលអត្ថបទនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ប៉ុន្តែនៅក្នុងសវនាការ នួន ជា បែជានិយាយថា ទស្សនាវដ្តីទង់បដិវត្តគឺជាសារនយោបាយរបស់អ្នកដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យដើម្បីទាក់ទងកម្លាំងកុម្មុយនីស្តកម្ពុជាពុំមែនជាអត្ថបទច្បាប់នោះទេ ។ នួន ជា បានបន្ថែមទៀតថា អត្ថបទភាគច្រើនគឺជាសេចក្តីថ្លែងការណ៍របស់ ប៉ុល ពត និងរបាយការណ៍តាមមូលដ្ឋាន ហើយមានតែ ប៉ុល ពត ប៉ុណ្ណោះជាអ្នកទទួលខុសត្រូវសរសេរអត្ថបទ និងបោះពុម្ពចុះផ្សាយ ពុំមែនគណៈមជ្ឈិមបក្សទេ ។ នួន ជា បានបន្តថា កាលនោះបើទោះបីជាគណៈមជ្ឈិមបក្សមើលឃើញថាមានកំហុសខ្លះនៅក្នុងអត្ថបទទាំងនោះក៏ដោយ ក៏ពុំមានអ្នកណាហ៊ាននិយាយឡើយដោយសារ ប៉ុល ពត គឺជាមនុស្សមានអំណាចខ្លាំងលើសគេ ។ នួន ជា បន្ថែមថា អ្វីដែល ប៉ុល ពត គិតថាគឺសុទ្ធតែតែទាំងអស់ ហើយអំណាចទាំងអស់នៅពេលនោះគឺស្ថិតលើលេខាបក្ស ប៉ុល ពត តែម្នាក់ប៉ុណ្ណោះ ។ ចំណុចសំខាន់មួយទៀត ដែលជនជាប់ចោទ នួន ជា បានឆ្លើយតបគឺពាក់ព័ន្ធនឹងការទាមទាររកឯកសារដើម ។ ស្ថិតនៅក្នុងការរក្សាជំហរដដែល នួន ជា បានស្នើសុំឲ្យមានការបង្ហាញនូវឯកសារដើមដោយផ្អែកលើហេតុផលធានានូវយថាភាពនៃឯកសារ ។ ជាចុងក្រោយ ជនជាប់ចោទ នួន ជា បានច្រានចោលឯកសារថតចម្លងទាំងអស់ រួមទាំងអត្ថបទដកស្រង់ចេញពីសៀវភៅមួយចំនួនដែលនិពន្ធដោយលោកដេវីដ ឆេនដ៍ល័រ, ហ្វីលីព ស្សត, ហ្វ្រង់ស៊័រ ប៉ុងសូ និង បែនឃៀនិន ជាដើម ដែលសហព្រះរាជអាជ្ញាប្រើប្រាស់បានដើម្បី ។ ជនជាប់ចោទ នួន ជា ក៏បានបញ្ជាក់ជូនអង្គជំនុំជម្រះទាក់ទងនឹងតួនាទីនិងការគ្រប់គ្រងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថា គាត់មានតួនាទីតែបី

ប៉ុណ្ណោះគឺ ៖ អនុលេខាបក្សកុម្មុយនីស្តកម្ពុជា ដែលមានតួនាទីផ្សព្វផ្សាយអប់រំសមាជិកបក្ស ហើយគាត់ពុំមានតួនាទីអប់រំឲ្យសមាជិកបក្សមានអាកប្បកិរិយាមិនគប្បីចំពោះប្រជាជន និងពុំដែលអប់រំឲ្យសមាជិកបក្សណាម្នាក់សម្លាប់ បង្អត់អាហារប្រជាជន ឬប្រព្រឹត្តអំពើប្រល័យពូជសាសន៍ម្តងណាទេ។ នួន ជា បានសរសើរខ្លួនឯងថា គាត់បានពង្រឹងផ្នែកសន្តិសុខជាតិដែលនេះជាតួនាទីរបស់ថ្នាក់ដឹកនាំទូទៅ ឧទាហរណ៍ថ្មីៗនេះ សហរដ្ឋអាមេរិក បានចេញសេចក្តីសម្រេចតាមចាប់ខ្លួនលោក អេដវ៉ាដ ស្នូឌេន ដោយសារតែបុគ្គលរូបនេះធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ។ នួន ជា បានបន្តថា គាត់បានធ្វើជាអ្នកចរចា និងសម្របសម្រួលជាច្រើនជាមួយវៀតណាម ដើម្បីសន្តិភាព ប៉ុន្តែកិច្ចការនេះមិនបានសម្រេច ដោយសារតែវៀតណាមនៅតែព្យាយាមបន្តឈ្លានពានប្រទេសកម្ពុជា។ តួនាទីចុងក្រោយគឺជាប្រធានសភាតំណាងប្រជាជនដែលទទួលខុសត្រូវក្នុងការអនុម័តច្បាប់។ ជនជាប់ចោទ នួន ជា បានធ្វើការច្រានចោលចំពោះតួនាទីផ្សេងពីតួនាទីខាងលើដូចជាតួនាទីនាយករដ្ឋមន្ត្រីស្តីទីរបស់ ប៉ុល ពត, គណៈកម្មាធិការយោធា និងការជាប់ពាក់ព័ន្ធនឹង ការគ្រប់គ្រងមន្ទីរ ស-២១។

ស្ថិតនៅក្នុងឱកាសដែលអង្គជំនុំជម្រះផ្តល់ជូននូវឱកាសឆ្លើយចុងក្រោយសម្រាប់សវនាការសំណុំរឿង០០២ ដំណាក់កាលទី១នេះ ជនជាប់ចោទ ខៀវ សំផន បានក្រោកឈរដើម្បីជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ។ ហេតុផលដែល ខៀវ សំផន សម្រេចប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរដោយសារតុលាការពុំបានគោរពសិទ្ធិរបស់ខ្លួនក្នុងនាមជាជនជាប់ចោទនិងពុំបានគោរពសិទ្ធិមេធាវីរបស់ខ្លួន។ ជនជាប់ចោទ ខៀវ សំផន បានបន្តថា មុនដំបូង ខ្លួនជឿជាក់លើតុលាការនេះ ប៉ុន្តែបន្តបន្ទាប់រហូតដល់ដំណាក់កាលចុងក្រោយនេះ ខ្លួនអស់ជំនឿលើតុលាការនេះទៀតហើយ។ ខៀវ សំផន បានបន្ថែមថា មូលហេតុដែលបណ្តាលឲ្យខ្លួនពុំនៅរក្សាជំហរអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប ពុំមែនត្រឹមតែអង្គជំនុំជម្រះបានច្រានចោលការទុករយៈពេលមួយសម្រាប់ឲ្យជនជាប់ចោទត្រៀមខ្លួនឆ្លើយតបសំណួរ ក៏ដូចជាការផ្តល់នូវបញ្ជីសំណួរជាមុនមកជនជាប់ចោទនោះទេ។ មូល

ហេតុផ្សេងទៀតគឺដោយសារតែអង្គជំនុំជម្រះបានកម្រិតនូវចំនួនទំព័រសម្រាប់សារណាឆ្លើយតប និងកំហិតពេលវេលាខ្លីពេកក្នុងការផ្ញើសារណាផ្ទាល់មាត់ចំពោះក្រុមមេធាវីរបស់ខ្លួន។

ឆ្លើយតបទៅនិងការអះអាងរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន ជនរងគ្រោះម្នាក់មកពីខេត្តកោះកុងឈ្មោះ ដុន រឿន បាននិយាយថា ខ្មែរក្រហមបានដេញប្រជាជនចេញពីលំនៅដ្ឋានពិតប្រាកដមែន។ អ្នកដែលមិនព្រមចាកចេញនឹងត្រូវសម្លាប់។ រឿនបានបន្ថែមទៀតថា «មកដល់ពេលនេះហើយ នួន ជា នៅតែមិនព្រមភ្ញាក់ខ្លួនទៀត ហើយថែមទាំងថាប្រជាជនចេញដោយការស្ម័គ្រចិត្តទៀត។ គ្មាននរណាជឿគាត់ទេ» ។ សែម ផាម មកពីខេត្តកំពង់ធំបានអះអាងស្រដៀងទៅនិង រឿន ដែរថា ពុំមានការជម្លៀសដោយស្ម័គ្រចិត្តទេ គ្មាននរណាម្នាក់សប្បាយចិត្តក្នុងការចាកចេញពីផ្ទះសម្បែងរបស់ខ្លួនទេ។ នៅក្នុងរបបសង្គមនិយម អ្នកនៅថ្នាក់ក្រោមតែងតែអនុវត្តតាមបញ្ជារបស់ខាងលើជានិច្ចគឺយោធាខ្មែរក្រហមធ្វើតាមតែបញ្ជាពីថ្នាក់លើដែលមានរូមបញ្ចូលទាំង នួន ជា និង ខៀវ សំផន នេះឯង។

**- ចប់ -**